**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការខេត្តកំពង់ធំ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៤០១ ចុះថ្ងៃទី ២២
ខែ សីហា ឆ្នាំ ២០០៥
សាលក្រម
លេខ ០៦ "ក" ចុះថ្ងៃទី ១០
ខែ កុម្ភៈ ឆ្នាំ ២០០៦

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តកំពង់ធំ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះ នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ ក ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តកំពង់ធំ នៅ ១០ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

ចៅក្រមជំនុំជំរះ
លោក [redacted]
តំណាងអយ្យការ
លោក [redacted]
ក្រឡាបញ្ជីសវនាការ
លោក [redacted]

សាលក្រមនេះចូលជាស្ថាពរចាប់តាំងពីថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៦
តទៅដោយផុតកំណត់ពេលប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។
កំពង់ធំ, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៦
ប្រធានតុលាការខេត្ត
[redacted]

**ដើម្បីជំនុំជំរះ**

លើជនជាប់ចោទ ជនមិនស្គាល់មុខ "គ្មានសារំគារជាតិ" ។

ជាប់ចោទពីបទ : ប្រើប្រាស់រណាយន្តអារច្រៀកឈើព្រៃឈើ ដោយគ្មា អនុញ្ញាតពីរដ្ឋបាលព្រៃឈើ ប្រព្រឹត្តនៅចំណុច UTM (០៥៣៩៥៥៤៩-១៤២៥ ឃុំទីរឹង ស្រុកសណ្តាន់ ខេត្តកំពង់ធំ កាលពីថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៥ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៩៥ ខណ្ឌទី១ ចំណុច១ នៃច្បាប់ស្តីពីព្រៃឈើ ។

-បានឃើញដីកាសន្និដ្ឋានចោទប្រកាន់ជូនរឿងទៅជំនុំជំរះផ្ទាល់លេខ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៥ របស់អយ្យការអមតុលាការខេត្តកំពង់ធំ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ១២៣១ ចុះថ្ងៃទី សីហា ឆ្នាំ ២០០៥ របស់តុលាការខេត្តកំពង់ធំ ។

## ការប្រព្រឹត្តិរបស់ជនជាប់ចោទ

កាលពីថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៥ សមត្ថកិច្ចសង្កាត់រដ្ឋបាល ទីរឹង បានចុះប្រតិបត្តិការនៅ ចំណុច UTM (០៥៣៩៥៥៤៩-១៤២៥២១៥ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ប្រទះឃើញជនល្មើសអារឈើ តែពេលសមត្ថកិ កន្លែងកើតហេតុ ជនល្មើសបានរត់គេចខ្លួនបាត់ ដោយបន្សល់ទុករណាយន្ត ម៉ាកស៊ីល០៧០ នៅនឹងកន្លែងហើយសមត្ថកិច្ចបានយកមកប្រគល់ឱ្យលោក ចា



Scanned with CamScanner

ទទួលថែរក្សាជាបណ្តោះអាសន្ន ។

-បានឃើញកំណត់ហេតុបទល្មើសជាក់ស្តែង ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៥ របស់សមត្ថកិច្ចសង្កាត់រដ្ឋបាលព្រៃឈើទីរីង បញ្ជាក់ថា :

១-កន្លែងកើតហេតុនៅចំណុច UTM (០៥៣៥៥៤៥-១៤២៥២១៩) ឃុំទីរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។

២-ប្រភេទបទល្មើសប្រើប្រាស់រណារយន្តអារច្រៀកឈើ ដោយគ្មានលិខិតអនុញ្ញាតពីរដ្ឋបាលព្រៃឈើ ។

៣-វត្ថុតាងមានរណារយន្ត ០១គ្រឿង ម៉ាកស្ទីល០៧០ ។

៤-ប្រព្រឹត្តដោយជនមិនស្គាល់មុខ

៥-នៅពេលត្រួតពិនិត្យជនល្មើសគ្មាន

៦-បន្ទាប់ពីបានពិនិត្យជាក់ស្តែងឃើញថា ប្រើប្រាស់រណារយន្តអារច្រៀកឈើខាងលើប្រាសចាកពីច្បាប់ស្តីពីព្រៃឈើ ហើយបានបញ្ជូនកំណត់ហេតុអំពើល្មើសជាក់ស្តែងនេះ ទៅសមត្ថកិច្ចថ្នាក់លើដើម្បីសំរេច ។

-បានឃើញកំណត់ហេតុនៃបទល្មើស ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៥ របស់នាយផ្នែករដ្ឋបាលព្រៃឈើសណ្តាន់ បានបញ្ជាក់ថា នៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ វេលាម៉ោង ៧:៣០នាទីព្រឹក យើងបានទទួលរបាយការណ៍លេខ ៥១ សរពទ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៥ របស់សង្កាត់រដ្ឋបាលព្រៃឈើទីរីង ស្តីពីការចាប់ឃាត់រណារយន្ត ០១គ្រឿង នៅចំណុច UTM (០៥៣៥៥៤៥-១៤២៥២១៩) ឃុំទីរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ដោយជនមិនស្គាល់មុខ ។ រីឯវត្ថុតាងត្រូវបានដឹកប្រគល់ឱ្យលោក ឈូ [redacted] ថែរក្សាបណ្តោះអាសន្ន ។

-បានឃើញលិខិតទទួលថែរក្សា ចុះថ្ងៃទី ១៣ ខែ. កក្កដា ឆ្នាំ ២០០៥ បញ្ជាក់ថា ឈ្មោះ ឈូ [redacted] បានទទួលថែរក្សាវត្ថុតាងមាន រណារយន្ត ០១គ្រឿង ម៉ាកស្ទីល០៧០ ។

## នារពេលសទនាការ

លោក អ៊ុន [redacted] នាយរងសង្កាត់រដ្ឋបាលព្រៃឈើទីរីង ជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយថា កាលពីថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៥ សមត្ថកិច្ចសង្កាត់រដ្ឋបាលព្រៃឈើទីរីង បានចុះប្រតិបត្តិការប្រទះឃើញជាក់ស្តែងជនល្មើសកំពុងអារឈើ នៅចំណុច UTM (០៥៣៥៥៤៥-១៤២៥២១៩) ឃុំទីរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ តែពេលសមត្ថកិច្ចទៅដល់ជនល្មើសបានរត់គេចខ្លួនបាត់បន្សល់ទុករណារយន្ត ០១គ្រឿង ម៉ាកស្ទីល០៧០ ហើយសមត្ថកិច្ចយករណារវត្ថុតាងនោះ មកប្រគល់ឱ្យលោក ឈូ [redacted] ទទួលថែរក្សាជាបណ្តោះអាសន្ន ។ សំណូមពរតុលាការរឹបអូសវត្ថុតាងជាប្រយោជន៍សម្បត្តិរដ្ឋ ។

តំណាងអយ្យការធ្វើសន្និដ្ឋានថា មានពិរុទ្ធភាពចួនល្មមលើជនជាប់ចោទ ជនមិនស្គាល់មុខ ពីបទ : ប្រើប្រាស់រណារយន្តអារច្រៀកឈើ ដោយគ្មានលិខិតអនុញ្ញាតពីរដ្ឋបាលព្រៃឈើ ប្រព្រឹត្តនៅចំណុច UTM (០៥៣៥៥៤៥-១៤២៥២១៩) ឃុំទីរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ កាលពីថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៥ ។ ដូច្នេះអយ្យការសំរេចតំកល់ដីកាសន្និដ្ឋានចោទប្រកាន់ជូនរឿងជំនុំជំរះផ្ទាល់លេខ : ៧៦ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៥ របស់អយ្យការទុកជាបានការពេញទាំងមូល និង សុំតុលាការសំរេចរឹបអូសវត្ថុតាង ជាប្រយោជន៍សម្បត្តិរដ្ឋ ។



Scanned with CamScanner

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានពិនិត្យភស្តុតាង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការខេត្តកំពង់ធំ**

**យល់ឃើញថា**

-កាលពីថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៥ សមត្ថកិច្ចសង្កាត់រដ្ឋបាលព្រៃឈើទីរ៉ង បានចុះប្រតិបត្តិកា ប្រទះឃើញជាក់ស្តែងជនល្មើសកំពុងអារឈើនៅចំណុច UTM (០៥៣៩៥៥៤៩-១៤២៥២១៩) ឃ ទីរ៉ង ស្រុកសណ្តាន់ ខេត្តកំពង់ធំ តែពេលសមត្ថកិច្ចចូលទៅដល់ជនល្មើសបានរត់គេចខ្លួនបាត់អស់ ដោយ បន្សល់ទុករណាយន្ត ០១គ្រឿង ម៉ាកស៊ីល០៧០ ហើយសមត្ថកិច្ចបានយកវត្ថុតាងនោះមកប្រគល់ឱ លោក ហួ គឹមឆេង ទទួលថែរក្សាជាបណ្តោះអាសន្ន ។

-អំពើល្មើសនេះមានបញ្ញត្តិច្បាប់ចែងជាបទល្មើសប្រើប្រាស់រណាយន្តអារច្រៀកឈើព្រៃឈើ ដោយគ្មា លិខិតអនុញ្ញាតពីរដ្ឋបាលព្រៃឈើ ល្មើសបញ្ញត្តិមាត្រា ៧០ កថាខណ្ឌទី៣ និង ទី៤ ឱ្យផ្តន្ទាទោសតា បញ្ញត្តិមាត្រា ៩៩ ចំណុចទី១ នៃច្បាប់ស្តីពីព្រៃឈើ ។

-សមត្ថកិច្ចរដ្ឋបាលព្រៃឈើបានប្រកាសរកជនល្មើស ឱ្យបង្ហាញលិខិតអនុញ្ញាតក្នុងរយៈពេល ៣០ថ្ងៃ តាមកំណត់ច្បាប់ហើយ តែគ្មានជនណាម្នាក់ចេញមុខបង្ហាញលិខិតអនុញ្ញាតទេ ។

-រណាយន្តវត្ថុតាងម៉ាកស៊ីល០៧០ មួយគ្រឿង ដែលសមត្ថកិច្ចប្រមូលបានពីកន្លែងកើតហេតុ គឺពិតជាវ តាង នៃអំពើល្មើសច្បាប់ក្នុងបទចោទប្រកាន់នេះប្រាកដមែន ។

**ហេតុដូច្នេះតុលាការខេត្តកំពង់ធំ**

**វិនិច្ឆ័យសេចក្តី**

១-បង្គង់បណ្តឹងអាជ្ញាលើជនជាប់ចោទមិនស្គាល់មុខ"អញ្ញាតជន" គ្មានសាវតារជាតិ ពីបទ **ប្រើប្រាស់រណា យន្តអារច្រៀកឈើ ដោយគ្មានលិខិតអនុញ្ញាតពីរដ្ឋបាលព្រៃឈើ** ប្រព្រឹត្តនៅចំណុច UTM (០៥៣ ៩៥៤៩-១៤២៥២១៩) ឃុំទីរ៉ង ស្រុកសណ្តាន់ ខេត្តកំពង់ធំ កាលពីថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៥

២-សំរេចរឹបអូសវត្ថុតាងមាន : រណាយន្ត ០១គ្រឿង ម៉ាកស៊ីល០៧០ ជាប្រយោជន៍សម្បត្តិរដ្ឋ ។

៣-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខលោក អ៊ុន មុត្ត តំណាងដើមបណ្តឹង រដ្ឋប្បវេណី ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល២ខែ តាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជំរះ**

**បានឃើញ** **ហត្ថលេខានិងត្រា :** [redacted]

**ប្រធានតុលាការខេត្ត**

[redacted]



Scanned with CamScanner